ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ.២១៦៣.អពដ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ២០១៦

# សេចក្តីណែនាំ
## ស្តីពីការប្រើប្រាស់លេខរៀងវិក្កយបត្រ
## សម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស

អនុលោមតាមមាត្រា៧៧ មាត្រា៧៨ និងមាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម (អតប) ព្រមទាំងសេចក្តីណែនាំលេខ ១១២៧ អពដ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស អ្នកជាប់ពន្ធទាំងអស់ត្រូវចេញវិក្កយបត្រលើរាល់ការលក់ ឬផ្គត់ផ្គង់ទំនិញឬសេវា តាមគំរូដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំលេខ ១១២៧ អពដ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ និងត្រូវប្រើប្រាស់វិក្កយបត្រតាមលំដាប់លេខរៀងឱ្យបានត្រឹមត្រូវ។

ក្នុងការពង្រឹងការគ្រប់គ្រងប្រមូលចំណូលសារពើពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងធានាដល់យន្តការត្រួតពិនិត្យសារពើពន្ធ ឱ្យបានកាន់តែច្បាស់លាស់ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំអំពីការប្រើប្រាស់លេខរៀងវិក្កយបត្រ ដូចខាងក្រោម÷

ក. ត្រូវប្រើប្រាស់វិក្កយបត្រតាមលំដាប់លេខរៀងពេញមួយឆ្នាំ និងត្រូវរក្សាទុកជាឯកសារ សម្រាប់គោលដៅពន្ធដារ រយៈពេល ១០ ឆ្នាំ សម្រាប់អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំ និងរយៈពេល ០៣ឆ្នាំ សម្រាប់អ្នកជាប់ពន្ធតូច

ខ. អ្នកជាប់ពន្ធអាចប្រើតួអក្សរនៅពីមុខលេខលំដាប់វិក្កយបត្រ សម្រាប់សម្គាល់ទីកន្លែងចេញវិក្កយបត្ររបស់ការិយាល័យកណ្តាល (Head Office) ឬសាខាដែលទទួលស្គាល់ដោយអគ្គនាយកដ្ឋានពន្ធដារ និងត្រូវមានលំដាប់លេខរៀងវិក្កយបត្រតាមស្តង់ដារតែមួយប៉ុណ្ណោះ (ឧទាហរណ៍÷ PPCI-0001, PPCI-0002, PPCI-0003,... និង PPTI-0001, PPTI-0002, PPTI-0003,... ឬ SRCI-0001, SRCI-0002, SRCI-0003,... និង SRTI-0001, SRTI-0002, SRTI-0003,...)។ ចំពោះអ្នកជាប់ពន្ធមានសាខាគឺត្រូវចេញខ្សែវិក្កយបត្រតាមសាខានីមួយៗ ដាច់ដោយឡែកពីគ្នា និងផ្សេងគ្នាពីការិយាល័យកណ្តាល (Head Office) ហើយត្រូវបែងចែកវិក្កយបត្រជាពីរខ្សែគឺវិក្កយបត្រអាករ (Tax Invoice) និងវិក្កយបត្រធម្មតា (Commercial Invoice)

គ. មិនអនុញ្ញាតឱ្យប្រើតួអក្សរផ្សេងៗគ្នានៅពីមុខលេខលំដាប់ខ្សែវិក្កយបត្រតែមួយ ក្នុងគោលដៅធ្វើការបែងចែកវិក្កយបត្រទៅតាមប្រភេទអតិថិជន តាមផលិតផល តាមតំបន់ តាមសកម្មភាព និងតាមប្រភេទផ្សេងៗទៀតឡើយ

ឃ. ចំពោះអ្នកជាប់ពន្ធដែលចេញវិក្កយបត្រតាមម៉ាស៊ីនគិតលុយ (POS) អ្នកជាប់ពន្ធអាចចេញលំដាប់លេខរៀងវិក្កយបត្រទៅតាមម៉ាស៊ីននីមួយៗបាន ប៉ុន្តែត្រូវរំលេចលេខសម្គាល់របស់ម៉ាស៊ីនលើវិក្កយបត្រនោះ ព្រមទាំងត្រូវរាយការណ៍ឱ្យបានត្រឹមត្រូវអំពីចំនួនម៉ាស៊ីន ត្រឹមដំណាច់ខែមករា ឆ្នាំ២០១៧ និងត្រូវជូនដំណឹងរាល់ការផ្លាស់ប្តូរម៉ាស៊ីន មកអគ្គនាយកដ្ឋានពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោក-លោកស្រីជាម្ចាស់ និងជាបណ្ណាធិការ នៃសហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ បានយ៉ាងខ្ជាប់ខ្ជួន ប្រកបដោយតម្លាភាព និងស្មារតីទទួលខុសត្រូវ ព្រមទាំងកិច្ចសហការខ្ពស់។

អគ្គនាយកដ្ឋាន
ពន្ធដារ

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល